00901326

E236/5/4

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception):
24 / 04 / 2013
ម៉ោង (Time/Heure): 11:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**សាធារណៈ / Public**

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៣

**ជូនចំពោះ៖** ភាគីនៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក /លោកស្រីចៅក្រម, មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង អង្គភាពគាំពារសាក្សី និងអ្នកជំនាញ, ការិយាល័យរដ្ឋបាល

**កម្មវត្ថុ៖** សេចក្តីសម្រេចស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-277 និង TCW 84 ពាក់ព័ន្ធនឹងអត្តចរិតរបស់ ខៀវ សំផន តាមរយៈប្រព័ន្ធសោតទស្សន៍

មេធាវីការពារក្តី ខៀវ សំផន ស្នើសុំសួរ សាក្សីចំនួន ០៥ រូប ពាក់ព័ន្ធនឹងអត្តចរិតរបស់ជនជាប់ចោទ ខៀវ សំផន ដែលក្នុងនោះរួមមាន សាក្សីដែលមានរហស្សនាម TCW-277 និង TCW-84 ដែលកំពុងរស់នៅឯប្រទេសបារាំង (ឯកសារ E236)។ មេធាវីការពារក្តីបានគូសបញ្ជាក់ថា សាក្សីទាំង ០២ រូបនេះនឹងផ្តល់សក្ខីកម្មត្រឹមតែអំពីអត្តចរិតរបស់ជនជាប់ចោទប៉ុណ្ណោះ ហើយសាក្សីម្នាក់ៗនឹងផ្តល់សក្ខីកម្មចំនួនប្រមាណជាមួយម៉ោងកន្លះ។ ការសម្រេចថា តើត្រូវស្តាប់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍ ឬមិនស្តាប់នោះ គឺជាឆន្ទានុសិទ្ធិ របស់អង្គជំនុំជម្រះ។ នៅក្នុងករណីនេះ អង្គជំនុំជម្រះចាត់ទុកថាជាការពុំចាំបាច់ដើម្បីនាំសាក្សីទាំង ០២ រូបនេះពីប្រទេសបារាំងមកប្រទេសកម្ពុជា គ្រាន់តែដើម្បីស្តាប់សក្ខីកម្មពាក់ព័ន្ធនឹងអត្តចរិតសម្រាប់រយៈពេលដ៏ខ្លីបែបនេះនោះទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចថាការសួរសាក្សីដែលមានរហស្សនាម TCW-277 និង TCW-84 ពីភាគី និងអង្គជំនុំជម្រះត្រូវធ្វើតាមរយៈប្រព័ន្ធសោតទស្សន៍ពីប្រទេសបារាំង។ អង្គជំនុំជម្រះបង្គាប់ឲ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញធ្វើការរៀបចំដែលចាំបាច់ទាំងអស់ជាមួយផ្នែកពាក់ព័ន្ធដើម្បីត្រៀមសម្រាប់សក្ខីកម្មតាមរយៈប្រព័ន្ធ

សោតទស្សន៍របស់សាក្សីទាំង ០២ រូបនេះ នៅក្នុងសវនាការនាពេលរសៀល នៅថ្ងៃអង្គារ៍ ទី ២១ ខែ ឧសភា ឆ្នាំ ២០១៣ និងបន្តទៀតនៅរសៀលថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៣ ទៅតាមការចាំបាច់។